Institut Pasteur du Cambodge

*រៀបរៀងដោយ វេជ្ជ. ហេង សៃឃឹម / វេជ្ជ. ពឹង យ៉ីកស៊ីង / ខែមេសា ឆ្នាំ២០១៥*

# វ៉ាក់សាំងបង្ការជំងឺ ៥មុខ

## (ខាន់ស្លាក់ - តេតាណូស - ក្អកមាន់ - ស្វិតដៃជើង - អេម៉ូហ្វីលីសប្រភេទបេ)

### ១- ហេតុអ្វីអ្នកត្រូវទទួលវ៉ាក់សាំងប្រភេទនេះ?

**- ជំងឺខាន់ស្លាក់**

ការបង្ករោគដោយមេរោគខាន់ស្លាក់អាចបណ្តាលអោយមានភ្នាសក្រាស់ នៅផ្នែកខាងក្រោយនៃបំពង់ក ដែលអាចអោយមានអាការៈពិបាកដកដង្ហើម សាច់ដុំចុះខ្សោយ វិបត្តិបេះដូងសរសៃឈាម និងអាចស្លាប់បាន។

**- ជំងឺតេតាណូស**

ការបង្ករោគដោយមេរោគតេតាណូសអាចបណ្តាលអោយមានអាការៈឈឺសាច់ដុំ និងកន្ត្រាក់រឹងខ្លួនទាំងមូល ការកន្ត្រាក់ខ្លាំងដល់រឹងថ្គាម បណ្តាលអោយអ្នកជំងឺមិនអាចហាមាត់ រឺលេបអាហារបានឡើយ។ ជំងឺតេតាណូសនេះ អាចបណ្តាល អោយស្លាប់ប្រមាណជា ២០ភាគរយនៃករណីជំងឺ។

**- ជំងឺក្អកមាន់**

ការបង្ករោគដោយមេរោគក្អកមាន់អាចបណ្តាលអោយមានអាការៈក្អកជាប់គ្នាមិនដាច់ ដែលវាអាចបណ្តាលអោយកុមារតូចៗមិនអាចបៅ រឺផឹកបាន ហើយអាការៈនេះអាចមានរយៈពេលយូររហូតដល់ច្រើនសប្តាហ៍។ វាអាចមានផលវិបាកធ្ងន់ធ្ងរផ្សេងៗទៀត ដូចជា រលាកសួត ប្រកាច់ ខូចខួរក្បាល រឺ ស្លាប់។

**- ជំងឺស្វិតដៃជើង**

ជាទូទៅ ការបង្ករោគដោយមេរោគគ្រុនស្វិតដៃជើងមិនបណ្តាលអោយមានជំងឺធ្ងន់ធ្ងរឡើយ ក៏ប៉ុន្តែពេលខ្លះ វាបង្កអោយមានភាពខ្វិនអវៈយវៈ (សាច់ដុំមិនអាចកំរើកបាន) និងរលាកស្រោមខួរក្បាល ហើយអាចបណ្តាលអោយស្លាប់បាន តាមរយៈការធ្វើអោយពិការសាច់ដុំដកដង្ហើម (ដកដង្ហើមលែងកើត)។

**- ជំងឺបង្កដោយអេម៉ូហ្វីលីសប្រភេទបេ (Hib B)**

អេម៉ូហ្វីលីសប្រភេទបេ គឺជាមេរោគដែលគេជួបញឹកញាប់ជាងគេ ក្នុងជំងឺរលាកស្រោមខួរ លើកុមារអាយុតិចជាង៥ឆ្នាំ ហើយអាចបណ្តាលអោយខូចខួរក្បាល រឺថ្លង់បាន។ មេរោគនេះក៏អាចបណ្តាលអោយមានផលវិបាកមួយចំនួនទៀត ដូចជា រលាកសួត ឈឺបំពង់ក រលាកសន្លាក់ឆ្អឹង និងស្លាប់បាន។

### ២- តើកុមារគួរទទួលវ៉ាក់សាំងបង្ការជំងឺនេះនៅពេលណា?

កុមារត្រូវទទួលវ៉ាក់សាំងនេះ ចំនួន ៥ ដង៖

- ដូសទី១: នៅពេលកុមារមានអាយុ ១ ខែកន្លះ
- ដូសទី២: នៅពេលកុមារមានអាយុ ២ ខែកន្លះ
- ដូសទី៣: នៅពេលកុមារមានអាយុ ៣ ខែកន្លះ
- ដូសទី៤: នៅពេលកុមារមានអាយុ ១៨ ខែ
- ដូសទី៥: នៅពេលកុមារមានអាយុ ៦-៧ ឆ្នាំ

ក្នុងករណីចាំបាច់ វ៉ាក់សាំងនេះត្រូវបានគេចាក់រំលឹករាល់ ១០ ឆ្នាំម្តង។

### ៣- តើកុមារណាខ្លះដែលមិនគួរទទួលវ៉ាក់សាំងនេះ?

- កុមារដែលធ្លាប់មានប្រវត្តិប្រតិកម្មធ្ងន់ធ្ងរ ជាមួយវ៉ាក់សាំងប្រភេទនេះពីមុន ឬធ្លាប់ប្រតិកម្មធ្ងន់ធ្ងរជាមួយសមាសធាតុផ្សំផ្សេងទៀតដែលមាន ក្នុងវ៉ាក់សាំងនេះ
- កុមារដែលធ្លាប់មានអាការៈប្រកាច់ រឺជំងឺផ្នែកសរសៃប្រសាទ ក្នុងកំឡុងពេល ៧ ថ្ងៃក្រោយពីបានចាក់វ៉ាក់សាំងប្រភេទនេះ។

### ៤- ផលវិបាកដែលអាចកើតមានក្រោយពេលចាក់វ៉ាក់សាំងនេះ

ក៏ដូចជាឱសថផ្សេងៗទៀតដែរ វ៉ាក់សាំងអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរ ដូចជា ប្រតិកម្ម អាលែកស៊ី ជាដើម។ ប៉ុន្តែ លទ្ធភាពដែលវ៉ាក់សាំងបង្ការនេះអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរមានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន:

- ឈឺ ឬ ហើមត្រង់កន្លែងចាក់
- គ្រុនក្តៅ ឡើងកន្ទួលក្រហមលើស្បែក
- ប្រកាច់ សន្លប់ រឺ យំមិនឈប់ (កម្រមានណាស់)
- ប្រតិកម្មធ្ងន់ធ្ងរ (កម្រមានណាស់)

**ប្រសិនបើមានសញ្ញាប្រតិកម្មធ្ងន់ធ្ងរ សូមជូនដំណឹងដល់គ្រូពេទ្យជាបន្ទាន់!**